ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣០៦ សហវ.ប្រក

## ប្រកាសរួម
## ស្តីពី
## ការផ្តល់ប្រាក់ឧបត្ថម្ភបេបប្រជុំជូនក្រុមប្រឹក្សាស្តង់ដារជាតិ គណៈកម្មការបច្ចេកទេស និងលេខាធិការ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- ប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ
- ប្រកាសលេខ ២០៤ MIH/2016 ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពក្រុមប្រឹក្សាស្តង់ដារជាតិ
- យោងតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

អនុញ្ញាតឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្តល់ប្រាក់ឧបត្ថម្ភរបបប្រជុំជូនក្រុមប្រឹក្សាស្តង់ដារជាតិ និងលេខាធិការ តាមគោលការណ៍ ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| - ប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ | ចំនួន | ៨០.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - អនុប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ | ចំនួន | ៦៥.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - សមាជិកក្រុមប្រឹក្សាស្តង់ដារជាតិ | ចំនួន | ៥០.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - លេខាធិការក្រុមប្រឹក្សាស្តង់ដារជាតិ | ចំនួន | ៥០.០០០ | រៀល ក្នុង១ពេលប្រជុំ |

អនុញ្ញាតឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្តល់ប្រាក់ឧបត្ថម្ភរបបប្រជុំជូនគណៈកម្មការបច្ចេកទេស និងលេខាធិការ តាមគោលការណ៍ ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| - ប្រធានគណៈកម្មការបច្ចេកទេស | ចំនួន | ៥០.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - អនុប្រធានគណៈកម្មការបច្ចេកទេស | ចំនួន | ៤៥.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - សមាជិកគណៈកម្មការបច្ចេកទេស | ចំនួន | ៤០.០០០ | រៀល ក្នុង១ពេលប្រជុំ |
| - លេខាធិការគណៈកម្មការបច្ចេកទេស | ចំនួន | ៤០.០០០ | រៀល ក្នុង១ពេលប្រជុំ |

**ប្រការ ២ .-**

ប្រាក់ឧបត្ថម្ភរបបប្រជុំ ផ្តល់ជូនតែសាមីខ្លួនដែលបានចូលរួមប្រជុំជាក់ស្តែងប៉ុណ្ណោះ ដោយមានភ្ជាប់នូវបញ្ជីវត្តមាន និងរបាយការណ៍នៃកិច្ចប្រជុំ ។

ប្រាក់ឧបត្ថម្ភរបបប្រជុំ ផ្តល់ជូនគិតតាមចំនួនពេលនៃកិច្ចប្រជុំជាក់ស្តែង ក្នុងកម្រិតអតិបរមាមិនលើសពីរ (០២) ពេល ក្នុងមួយ (០១) ថ្ងៃធ្វើការ សម្រាប់កិច្ចប្រជុំពិភាក្សា និងអនុម័តស្តង់ដារនីមួយៗ។

**ប្រការ ៣ .-**

ក្រុមប្រឹក្សាស្តង់ដារជាតិ អាចប្រជុំពិភាក្សា និងអនុម័តស្តង់ដារចំនួនច្រើន ក្នុងកិច្ចប្រជុំមួយ (០១)ពេល ប៉ុន្តែការប្រជុំពិភាក្សា និងអនុម័តស្តង់ដារតែមួយ មិនត្រូវឱ្យលើសពីចំនួនពីរ (០២)ពេលប្រជុំឡើយ។

គណៈកម្មការបច្ចេកទេស អាចប្រជុំពិភាក្សា និងផ្តល់យោបល់លើស្តង់ដារចំនួនច្រើនក្នុងកិច្ចប្រជុំមួយ (០១)ពេល ប៉ុន្តែការប្រជុំពិភាក្សា និងផ្តល់យោបល់លើស្តង់ដារតែមួយ មិនត្រូវឱ្យលើសចំនួនប្រាំមួយ(០៦) ពេលប្រជុំឡើយ។

**ប្រការ ៤.-**

ប្រាក់ឧបត្ថម្ភរបបប្រជុំ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឥណទាន ក្នុងជំពូក ៦១ អនុគណនី ៦១១០៣ ។

**ប្រការ ៥ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុក អនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ចម ប្រសិទ្ធ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល</u>÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ